**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ: ០៨៣ [illegible]

ថ្ងៃសុក្រ ១៣កើត ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០២៦

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលមហាសន្និបាតភាគហ៊ុនិកលើកទី១៤
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនវិនិយោគិន និងសាធារណជន មេត្តាជ្រាបថា ៖ នាថ្ងៃសុក្រ ១៣កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦ ចាប់ពីម៉ោង ៨:០០ព្រឹក មហាសន្និបាតភាគហ៊ុនិកលើកទី១៤ របស់ រ.ទ.ស.ភ បានប្រព្រឹត្តទៅ តាមកម្មវិធីដែលបានគ្រោងទុក នៅស្នាក់ការ រ.ទ.ស.ភ និងតាមប្រព័ន្ធអនឡាញ ZOOM ក្រោមអធិបតីភាព **ឯកឧត្តម ឯក សុនចាន់** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ ដោយមានការចូលរួមពី **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា** ជាថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សមាជិកក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំ មន្ត្រី-និយោជិត រ.ទ.ស.ភ, ភាគហ៊ុនិក និងភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ។

មហាសន្និបាតនេះបានប្រព្រឹត្តទៅតាមរបៀបវារៈដូចបានកំណត់ទុក ដោយមានភាគហ៊ុនិកវត្តមានសរុប ២១៨រូប គិតជាភាគហ៊ុនមានចំនួន**៧៥.៥៥០.១៩៦** ស្មើនឹង**៨៦,៨៧%** នៃចំនួនភាគហ៊ុនធម្មតាសរុប និងទទួលបានលទ្ធផលដូចខាងក្រោម ៖

១- បានទទួលជ្រាបអំពីរបាយការណ៍លទ្ធផលអាជីវកម្មឆ្នាំ២០២៥ និងទិសដៅអាជីវកម្មឆ្នាំ២០២៦។

២- បានអនុម័តបែងចែកភាគលាភឆ្នាំ២០២៥ ជាសាច់ប្រាក់ចំនួន**២៨.៧០១.១៤៣.៤៦០រៀល** ជូនភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីភាគហ៊ុនិក នាកាលបរិច្ឆេទកំណត់ទុកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៦ (ក្នុងនោះទឹកប្រាក់ចំនួន៤.៣០៥.១៧១.៧៥០រៀល ជាភាគលាភដែលត្រូវបែងចែកជូនភាគហ៊ុនិកឯកជន និងទឹកប្រាក់ចំនួន២៤.៣៩៥.៩៧១.៧១០រៀល ជាភាគលាភរបស់រដ្ឋដែលតំណាងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសំឡេងឆ្នោតគាំទ្រចំនួន៧៥.៤៩៨.៥២៧សំឡេង ស្មើនឹង៩៩,៩៣% នៃចំនួនភាគហ៊ុនដែលមានវត្តមានសរុប។ ភាគលាភនេះនឹងត្រូវចែកជូនភាគហ៊ុនិក ចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ ដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៦ ក្នុងទឹកប្រាក់ចំនួន ៣៣០រៀល/ភាគហ៊ុន។

៣- បានអនុម័តលាភការរបស់សមាជិកក្រុមប្រឹក្សាភិបាលចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ចំនួន១រូប សម្រាប់ឆ្នាំ២០២៦ ដែលមានទឹកប្រាក់សរុបចំនួន**១.១០៧.៩៧៩.១៥២រៀល** ដោយសំឡេងឆ្នោតគាំទ្រចំនួន៧៥.៤៧៤.៦៦៩សំឡេង ស្មើនឹង៩៩,៩០% នៃចំនួនភាគហ៊ុនដែលមានវត្តមានសរុប។



អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ៣១ ៩៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

អង្គមហាសន្និបាតបានបញ្ចប់នៅវេលាម៉ោង១២:០០ថ្ងៃត្រង់ នាថ្ងៃខែនិងឆ្នាំដដែល ដោយស្ថិតក្រោមបរិយាកាសស្និទ្ធស្នាល រីករាយ និងទទួលខុសត្រូវ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបជាព័ត៌មាន។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**



អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ៣១ ៩៣៥ ៨០ ៨០ Email: admin@ppwsa.com.kh